# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**គណបក្សប្រជាធិបតេយ្យមូលដ្ឋាន**

សាមគ្គីភាព យុត្តិធម៌ អហិង្សា

## ឯកសារគោល

"ការបង្កើតគណបក្សប្រជាធិបតេយ្យមូលដ្ឋាន"

[អនុម័តដោយសមាជដំបូង ២ សីហា ២០១៥]

# ឯកសារគោល

ប្រទេសកម្ពុជា បានខិតខំប្រឹងប្រែងកសាងសង្គមប្រជាធិបតេយ្យមួយ ចាប់តាំងពីឆ្នាំ ១៩៩៣ ដោយឈរនៅលើកិច្ចព្រមព្រៀងស្តីពី ដំណោះស្រាយនយោបាយរួមមួយនៃជំលោះកម្ពុជា ដែលធ្វើនៅក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ (កិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស)។ ប៉ុន្តែទោះបីជាមានការខិតខំប្រឹងប្រែងយ៉ាងណាក៏ដោយ ក៏ដំណើរការកសាងប្រជាធិបតេយ្យនេះ នៅមានបញ្ហាប្រឈមច្រើន ដោយសារអ្នកនយោបាយខ្មែរនៅមានចរិតនិយមអំណាចប្រមូលផ្តុំទាំងក្នុងការដឹកនាំរដ្ឋ ក៏ដូចជាការដឹកនាំគណបក្សនយោបាយ។ ប្រជាពលរដ្ឋមិនត្រូវបានពន្យល់អប់រំ ឲ្យយល់ដឹងច្បាស់អំពីគោលគំនិត គោលការណ៍ ក៏ដូចជារូបរាងពិតប្រាកដរបស់ប្រជាធិបតេយ្យឡើយ។

ដោយហេតុនេះហើយ ទើបក្រុមការងារបណ្តាញសង្គម ខ្មែរដើម្បីខ្មែរ បានធ្វើការសិក្សាស្រាវជ្រាវ និងពិគ្រោះយោបល់ជាមួយតួអង្គពាក់ព័ន្ធ ជាពិសេសជាមួយតំណាងប្រពលរដ្ឋតាមមូលដ្ឋានក្នុងឃុំគំរូមួយចំនួន ដើម្បីចងក្រងឯកសារ និងផ្សព្វផ្សាយអំពីគោលគំនិត គោលការណ៍ និងប្រព័ន្ធប្រជាធិបតេយ្យ។ ជាលទ្ធផលមានការផ្តួចផ្តើមបង្កើត «គណបក្សប្រជាធិបតេយ្យមូលដ្ឋាន»មួយ ដែលមានគោលការណ៍ប្រជាធិបតេយ្យផ្ទៃក្នុងពីក្រោមមកលើ សមាជិកមានភាពជាម្ចាស់ ជាពិសេសស្វ័យភាពហិរញ្ញវត្ថុ និងបណ្តុះបណ្តាលអ្នកដឹកនាំបែបប្រជាធិបតេយ្យជាច្រើននៅតាមមូលដ្ឋាន និងតាមវិស័យ ក្នុងគោលបំណងរួមចំណែកកសាងសង្គមប្រជាធិបតេយ្យដ៏ពិតប្រាកដ និងល្អប្រពៃមួយ ដែលប្រជាពលរដ្ឋរស់នៅមានជីវិតថ្លៃថ្នូរ និងប្រទេសជាតិមានអធិបតេយ្យពេញលេញ។

## ១-ឈ្មោះគណបក្ស

«គណបក្សប្រជាធិបតេយ្យមូលដ្ឋាន» ដែលមានអក្សរកាត់ (**គ ប ម**)។

## ២-រូបសញ្ញាគណបក្ស

ត្រីកោណ (សមង្ស) តំណាងឲ្យប្រជាធិបតេយ្យពីក្រោមមកលើ យកមូលដ្ឋានជាធំ ដែលមានផ្ទៃខាងក្នុងពណ៌បៃតង ជ្រុងបាតពណ៌ក្រហម ជ្រុងទាំងសងខាងពណ៌ខៀវ និងអក្សរ «**គ ប ម**» ពណ៌សនៅចំកណ្តាលផ្ទៃទាំងមូល។

***ពណ៌និងអត្ថន័យ***

*ពណ៌បៃតង* តំណាងឲ្យ «ធម្មជាតិ កសិកម្ម និងប្រជាធិបតេយ្យមូលដ្ឋាន»។

*ពណ៌ក្រហម* តំណាងឲ្យ «ការតស៊ូ ព្យាយាម និងយុត្តិធម៌»។

*ពណ៌ខៀវ* តំណាងឲ្យ «ច្បាប់ សិទ្ធិ និងសេរីភាព»។

*ពណ៌ស* តំណាងឲ្យ «តម្លាភាព ស្មោះត្រង់ និងសុចរិតភាព»។

**៣-គុណតម្លៃ**

«សាមគ្គីភាព យុត្តិធម៌ អហិង្សា»។

**៤-ទស្សនវិស័យ** (គោលបំណងវែងឆ្ងាយ)

"ប្រជាពលរដ្ឋរស់នៅមានជីវិតថ្លៃថ្នូរ និងប្រទេសជាតិមានអធិបតេយ្យពេញលេញ"។

**៥-បេសកកម្ម**

"បណ្តុះអ្នកដឹកនាំល្អ និងកសាងមូលដ្ឋានគ្រឹះប្រជាធិបតេយ្យទូទាំងប្រទេស"។

**៦-គោលការណ៍គ្រឹះ**

៦.១-ស្ម័គ្រចិត្ត និងបើកចំហ

៦.២-សមាជិកធិបតេយ្យ (ប្រជាធិបតេយ្យផ្ទៃក្នុងបក្ស)

៦.៣-ប្រជាធិបតេយ្យបែបវិមជ្ឈការ

៦.៤-អ្នកដឹកនាំខាងលើដើរតួនាទីជាអ្នកសម្របសម្រួល និងពង្រឹងសមត្ថភាព សមាជិក និងប្រជាពលរដ្ឋទូទៅ

៦.៥-ភាពជាម្ចាស់ ជាពិសេសស្វ័យភាពហិរញ្ញវត្ថុ។

**៧-សមាជិកភាព**

យើងបែងចែកសមាជិកជា២ប្រភេទ គឺ*សមាជិកជំហរ* និង*សមាជិកគាំទ្រ*

*៧.១-សមាជិកជំហរ*

*ក. លក្ខណៈសម្បត្តិសមាជិកជំហរ* ៖

១-មានសីលធម៌ល្អ

២-ស្មោះត្រង់នឹងសមាជិក

៣-មានសមត្ថភាពយល់ដឹង និងដោះស្រាយបញ្ហាមូលដ្ឋានបានល្អ

៤-ចូលចិត្តពិភាក្សា បើកចំហ និងធ្វើការជាក្រុម

៥-គោរពគុណតម្លៃ និងគោលការណ៍របស់ **គ ប ម**

៦-មានមនសិការជាតិ គិតផលប្រយោជន៍រួម និង

៧-ទំនាក់ទំនងល្អជាមួយអ្នកជិតខាង និងសហគមន៍។

***ខ. សិទ្ធិរបស់សមាជិកជំហរ*** ៖

១-ឈរឈ្មោះឲ្យគេបោះឆ្នោតធ្វើជាអ្នកតំណាង

២-បោះឆ្នោត

៣-បញ្ចេញមតិយោបល់ ចូលរួមតាមដាន និងវាយតម្លៃការងាររបស់បក្ស និង

៤-ចូលរួមក្នុងការសម្រេចចិត្តផ្សេងៗរបស់បក្ស។

*គ. តួនាទី និងកាតព្វកិច្ចរបស់សមាជិកជំហរ ៖*

១-បង់វិភាគទានទ្រទ្រង់ និងចូលរួមសន្សំប្រាក់

២-ចូលរួមប្រជុំទៀងទាត់

៣-ចូលរួមធ្វើគោលនយោបាយ និងយុទ្ធសាស្ត្ររបស់ **គ ប ម**

៤-ចូលរួមផ្សព្វផ្សាយបន្ទូលក្ខន្តិកៈ និងគោលនយោបាយរបស់ **គ ប ម**

៥-ចូលរួមសកម្មភាពសង្គមផ្សេងៗរបស់ **គ ប ម** និង

៦-ត្រូវមានអ្នកគាំទ្រយ៉ាងតិច ១០នាក់ឡើងទៅ។

*៧.២-សមាជិកគាំទ្រ*

*លក្ខណៈសម្បត្តិសមាជិកគាំទ្រ ៖*

១-ផ្តល់ការគាំទ្រផ្សេងៗដល់ **គ ប ម**

២-ជួយផ្សព្វផ្សាយគោលការណ៍របស់ **គ ប ម** និង

៣-បង់វិភាគទានតាមការស្ម័គ្រចិត្ត។

## ៨-គោលការណ៍ហិរញ្ញវត្ថុ

*ក. ប្រភពថវិកាសម្រាប់ទ្រទ្រង់ គ ប ម*

១-វិភាគទានសមាជិកភាពរបស់សមាជិកជំហរ

២-ចំណូលពីការប្រាក់របស់ក្រុមសន្សំ និងការវិនិយោគផ្សេងៗ

៣-វិភាគទានស្ម័គ្រចិត្តរបស់សមាជិកគាំទ្រ និង

៤-ចំណូលស្របច្បាប់ផ្សេងៗ។

*ខ. គោលការណ៍ និងការគ្រប់គ្រងចំណូល-ចំណាយ*

១. តម្លាភាព និងគណនេយ្យភាព (បញ្ជីស្នាមចំណូល-ចំណាយ របាយការណ៍ហិរញ្ញវត្ថុ សវនកម្ម)

២. គោរពតាមគោលការណ៍ប្រតិបត្តិហិរញ្ញវត្ថុរបស់ **គ ប ម**

៣. មានគំរោងផែនការថវិកា និងខ្ទង់ចំណាយច្បាស់លាស់។

## ៩-គោលការណ៍សំខាន់ៗ និងរចនាសម្ព័ន្ធដឹកនាំរបស់ គ ប ម

### ៩.១-គោលការណ៍សំខាន់ៗក្នុងការរៀបចំរចនាសម្ព័ន្ធដឹកនាំបក្សៈ

ក-គណៈកម្មការដឹកនាំគណបក្សនៅថ្នាក់ឃុំ ត្រូវមានសមាសភាពមកពីតំណាងតាមភូមិ, គណៈកម្មការថ្នាក់ស្រុក ត្រូវមានសមាសភាពមកពីតំណាងតាមឃុំ, គណៈកម្មការថ្នាក់ខេត្ត ត្រូវមានតំណាងសមាសភាពមកពីតាមស្រុក, គណៈ

កម្មការថ្នាក់ជាតិ ត្រូវមានតំណាងមកពីតាមខេត្ត/រាជធានី។ គណៈកម្មការតាំងពីថ្នាក់មូលដ្ឋានដល់ថ្នាក់ជាតិ ត្រូវមានសមាសភាព ដែលជាតំណាងស្ត្រី និងយុវជន។

**ខ**-រាល់សមាជិកក្នុងរចនាសម្ព័ន្ធដឹកនាំថ្នាក់ឃុំ/សង្កាត់ ស្រុក/ខណ្ឌ ខេត្ត/រាជធានី និងជាតិ ត្រូវជ្រើសតាំងដោយឆ្លងកាត់ការបោះឆ្នោតប្រកបដោយសេរី និងយុត្តិធម៌តាមរយៈសមាជ។

**គ**-ការបោះឆ្នោតត្រូវគោរពគោលការណ៍សំឡេងភាគច្រើនដាច់ខាត ៥០%+១ (ហាសិបភាគរយបូកមួយ)។

**ឃ**-ញាតិលោហិត និងញាតិពន្ធទី១ (ប្ដី ប្រពន្ធ កូន បងប្អូន ឪពុកម្ដាយ បង្កើតក្មេក និងសាច់ថ្លៃ) ត្រូវហាមឃាត់នៅក្នុងសមាសភាពថ្នាក់ដឹកនាំចាប់ពីថ្នាក់ឃុំដល់ជាតិ (ក្នុងអង្គភាពគ្រប់គ្រងតែមួយ)។

**ង**-អាណត្តិនៃថ្នាក់ដឹកនាំគ្រប់កម្រិត មានរយៈពេល ៣ឆ្នាំ (អាចឈរបានតែពីរអណត្តិ)។

**ច**-សមាជិកដែលស្ថិតនៅក្នុងរចនាសម្ព័ន្ធថ្នាក់ដឹកនាំ នឹងអាចត្រូវបានបោះឆ្នោតដកចេញពីតួនាទីក្នុងចន្លោះអាណត្តិក្នុងករណីចាំបាច់ ឧទាហរណ៍ដូចជាការប្រព្រឹត្តផ្ទុយទៅនឹងគោលការណ៍ ឬក្រមសីលធម៌ ឬច្បាប់ ឬពុករលួយ ឬបក្សពួកនិយម ជាដើម ។ល។

**៩.២-គោលការណ៍សំខាន់ៗក្នុងការជ្រើសរើសតំណាង និងអ្នកដឹកនាំថ្នាក់ជាតិ និងក្រោមជាតិ**

**ក**-បេក្ខជនក្រុមប្រឹក្សាឃុំ/សង្កាត់ តំណាងរាស្ត្រគ្រប់ខេត្ត និងរាជធានី ត្រូវជ្រើសតាំងតាមរយៈការបោះឆ្នោតដោយសេរី និងយុត្តិធម៌ ដោយសមាជិកជំហរនៅតាមឃុំ/សង្កាត់ ខេត្ត និងរាជធានីនីមួយៗ។ យើងផ្ដល់អាទិភាពដល់អ្នកមូលដ្ឋាន ក្នុងការឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ (អ្នកនៅខេត្តណា ឈរតំណាងឲ្យខេត្តហ្នឹង)។

**ខ**-ប្រធាន ឬអនុប្រធានគណបក្ស មិនអាចក្លាយទៅជាបេក្ខជននាយករដ្ឋមន្ត្រីដោយស្វ័យប្រវត្តិទេ។ បេក្ខជននាយករដ្ឋមន្ត្រី ត្រូវបានបោះឆ្នោតជ្រើសតាំងដោយសមាជថ្នាក់ជាតិ។

**គ**-រាល់សមាជិកក្នុងរចនាសម្ព័ន្ធដឹកនាំ ចាប់ពីថ្នាក់ឃុំដល់ថ្នាក់ជាតិ ត្រូវប្រកាសទ្រព្យសម្បត្តិដោយចំហ នៅពេលទទួលតួនាទីក្នុងអង្គការចាត់តាំងរដ្ឋ។

**ឃ**-យើងរៀបចំឲ្យមានក្រុមការងារតាមជំនាញ ដើម្បីជួយរៀបចំគោលនយោ-

បាយថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ និងត្រៀមខ្លួនចូលរួមការងារដឹកនាំប្រទេសទៅតាមវិស័យនានា។

## ៩.៣-រចនាសម្ព័ន្ធដឹកនាំថ្នាក់មូលដ្ឋាន




### ៩.៣.១-សមាជរបស់សមាជិកជំហរ

ក-សមាជិកជំហរពី១០ ទៅ១០០នាក់។

ខ-សមាជសាមញ្ញ គឺប្រជុំ១ឆ្នាំម្តង (សេចក្តីជូនដំណឹងត្រូវធ្វើឡើងយ៉ាងតិច ២ សប្តាហ៍មុនថ្ងៃអង្គសមាជ)។

គ-អង្គសមាជសម្រេចលើកិច្ចការសំខាន់ៗដូចតទៅ៖

- ✓ ជ្រើសរើសគណៈកម្មការប្រតិបត្តិ
- ✓ ជ្រើសរើសបេក្ខភាពក្រុមប្រឹក្សាឃុំ/សង្កាត់
- ✓ អនុម័តលើបទបញ្ជាផ្ទៃក្នុង **<u>គ ប ម</u>** ថ្នាក់ឃុំ/សង្កាត់
- ✓ អនុម័តលើគំរោងថវិកាប្រចាំឆ្នាំរបស់ **<u>គ ប ម</u>** ឃុំ/សង្កាត់
- ✓ អនុម័តលើគោលនយោបាយអភិវឌ្ឍឃុំរបស់ **<u>គ ប ម</u>**។

ឃ-កូរ៉ុមសមាជចាប់ពី ១/២ (មួយភាគពីរ) នៃសមាជិកជំហរ។

ង-សមាជវិសាមញ្ញ ត្រូវបានរៀបចំក្នុងករណីមានការស្នើសុំជាលាយលក្ខណ៍អក្សរពី ១/៣ (មួយភាគបី) នៃសមាជិកជំហរ ឬចាប់ពី ១/២ (មួយភាគពីរ) នៃគណៈកម្មការប្រតិបត្តិ (សេចក្តីជូនដំណឹងត្រូវធ្វើឡើងយ៉ាងតិច១សប្តាហ៍មុនអង្គសមាជវិសាមញ្ញ)។

ច-សេចក្តីសម្រេច ត្រូវឈរលើគោលការណ៍ភាគច្រើនដាច់ខាត ៥០%+១ (ហាសិបភាគរយបូកមួយ) នៃសំឡេងរបស់សមាជិកវត្តមាន។

### ៩.៣.២-គណៈកម្មការប្រតិបត្តិត្រូវមានសមាសភាពដូចខាងក្រោម

ក-គណៈកម្មការប្រតិបត្តិ ត្រូវមានសមាជិកយ៉ាងតិចបំផុត៧នាក់

១. ប្រធាន ២. អនុប្រធាន ៣. ហេរញ្ញិក ៤. បេឡា

៥. តំណាងស្ត្រី ៦. តំណាងយុវជន ៧. លេខាធិការ

ខ-គណៈកម្មការប្រតិបត្តិ ត្រូវប្រជុំយ៉ាងតិចបំផុត ១ខែម្តង

គ-កូរ៉ុមប្រជុំ គឺចាប់ពី ៥នាក់ឡើងទៅ ហើយការសម្រេចយកតាមគោលការណ៍សំឡេងភាគច្រើនដាច់ខាត ៥០+១% (ហាសិបភាគរយបូកមួយ)។

ឃ-លក្ខណៈវិនិច្ឆ័យសមាជិកគណៈកម្មការប្រតិបត្តិឃុំ/សង្កាត់របស់ **គ ប ម**

១-មានចំណេះដឹង (ចំណេះដឹងពី **គ ប ម**, ពីប្រព័ន្ធអភិបាលកិច្ចបែបប្រជាធិបតេយ្យ, ចំណេះដឹងពីមូលដ្ឋាន និងជំនាញផ្សេងៗ)

២-មានសុចរិតភាព និងយុត្តិធម៌

៣-មានភាពជាគំរូ

៤-ហ៊ានលះបង់ពេលវេលាដើម្បីផលប្រយោជន៍រួម

៥-មានការទទួលខុសត្រូវខ្ពស់ មានសេចក្តីក្លាហាន និង

៦-មានសមត្ថភាពពន្យល់ និងសម្របសម្រួលការប្រជុំ។

## ៩.៤-អំពីការរៀបចំរចនាសម្ព័ន្ធដឹកនាំថ្នាក់ជាតិ

### ៩.៤.១-រចនាសម្ព័ន្ធដឹកនាំថ្នាក់ជាតិ

សមាជដំបូងដែលមានប្រតិភូតំណាង ៣០០នាក់ នឹងសម្រេចលើរចនាសម្ព័ន្ធដឹកនាំថ្នាក់ជាតិនៅពេលក្រោយ។

### ៩.៤.២-រចនាសម្ព័ន្ធដឹកនាំថ្នាក់ជាតិបណ្តោះអាសន្ន

ការប្រជុំដំបូងដើម្បីត្រៀមខ្លួនជូនដំណឹង
(តំណាងតាមឃុំ/សង្កាត់ និងតាមក្រុម/វិស័យ)

គណៈកម្មការបណ្តោះអាសន្នថ្នាក់ជាតិ (យ៉ាងតិចបំផុត ៧នាក់ យ៉ាងច្រើនបំផុត ២១នាក់)

យើងត្រូវការសមាជិកជំហរ យ៉ាងតិចបំផុត៨០នាក់ ដើម្បីធ្វើការជូនដំណឹងដល់ក្រសួងមហាផ្ទៃស្តីពី ការបង្កើត **គ ប ម**។ យើងគ្រោងជ្រើសរើសសមាជិកជំហរមកពីឃុំ/សង្កាត់គំរូ១០។ សម្រាប់ការជូនដំណឹងដំបូង យើងត្រូវមានគណៈកម្មការបណ្តោះអាសន្ន ដែលមានសមាជិកយ៉ាងតិចបំផុត ៧នាក់ ដែលត្រូវមានសមាសភាពដូចជាៈ

១. ប្រធាន

២. អនុប្រធាន

៣. អគ្គលេខាធិការ
៤. ហេរញ្ញិក
៥. តំណាងស្ត្រី
៦. តំណាងយុវជន និង
៧. សមាជិក។

សមាសភាពរបស់គណៈកម្មការបណ្ដោះអាសន្ន ត្រូវបានជ្រើសតាំងឡើងតាមរយៈការបោះឆ្នោតដោយការប្រជុំពេញអង្គដំបូង។ ក្រោយពេលជូនដំណឹងជាផ្លូវការហើយ **<u>គ ប ម</u>** នឹងរៀបចំលក្ខន្តិកៈនិងរចនាសម្ព័ន្ធផ្លូវការ ដើម្បីត្រៀមខ្លួនចូលរួមបោះឆ្នោតឃុំ/សង្កាត់នៅឆ្នាំ២០១៧ និងការបោះឆ្នោតថ្នាក់ជាតិឆ្នាំ ២០១៨។

➔ **កំណត់សម្គាល់បន្ថែម ៖**

១. ឯកសារគោលនេះ នឹងត្រូវកែលម្អបន្ថែមដោយសមាជិកស្ថាបនិក **<u>គ ប ម</u>** និងត្រូវអនុម័តឲ្យប្រើប្រាស់ដោយសមាជិកជំហរ **<u>គ ប ម</u>**។

២. យើងនឹងរៀបចំឲ្យមានលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ **<u>គ ប ម</u>** ដាច់ដោយឡែក ហើយឯកសារទាំងនោះនឹងត្រូវអនុម័ត ដោយសមាជជាផ្លូវការនៅឆ្នាំ ២០១៦។

៣. យើងនឹងរៀបចំឲ្យមានគោលនយោបាយ និងកម្មវិធីនយោបាយរបស់ **<u>គ ប ម</u>** ដែលនឹងត្រូវអនុម័តនៅឆ្នាំ២០១៦។

**ឧបសម្ព័ន្ធ១៖ តួនាទីនៃរចនាសម្ព័ន្ធដឹកនាំថ្នាក់ជាតិបណ្ដោះអាសន្ន**

**ក-តួនាទីគណៈកម្មការបណ្ដោះអាសន្ន**

១-ជ្រើសតាំង និងត្រួតពិនិត្យគណៈកម្មការប្រតិបត្តិសម្រាប់បំពេញការងារប្រចាំថ្ងៃ

២-អនុម័ត និងត្រួតពិនិត្យលើគំរោងថវិកាប្រចាំឆ្នាំរបស់ គ ប ម ថ្នាក់ជាតិ

៣-អនុម័តលើគោលការណ៍ប្រតិបត្តិ និងសេចក្ដីណែនាំផ្សេងៗរបស់ គ ប ម

៤-សម្របសម្រួលពង្រឹងពង្រីក គ ប ម

៥-សម្របសម្រួលទំនាក់ទំនងជាមួយស្ថាប័នពាក់ព័ន្ធ

**ខ-តួនាទី និងគុណវុឌ្ឍិប្រធាន គ ប ម**

***ខ.១-តួនាទី***

១-សម្របសម្រួលកិច្ចប្រជុំគណៈកម្មការបណ្ដោះអាសន្ន និងគណៈកម្មការអចិន្ត្រៃយ៍

២-ជួបប្រជុំជាមួយអង្គការជាតិ អន្តរជាតិ តំណាងស្ថានទូត និងអ្នកមានចំណាប់អារម្មណ៍ដើម្បីផ្សព្វផ្សាយអំពី **គ ប ម** និងស្វែងរកការគាំទ្រសំរាប់ **គ ប ម**

៣-រៀបចំអង្គសមាជដំបូង

៤-ពង្រឹង និងពង្រីក **គ ប ម** តាមមូលដ្ឋាន និងថ្នាក់ជាតិ។

***ខ.២-គុណវុឌ្ឍិ***

១-មានសីលធម៌ល្អ និងមានស្មារតីលះបង់

២-មានបទពិសោធន៍ក្នុងការងារដឹកនាំស្ថាប័ន

៣-មានសមត្ថភាពសម្របសម្រួល និងទំនាក់ទំនង។

**គ-តួនាទី និងគុណវុឌ្ឍិអនុប្រធាន គ ប ម**

***គ.១-តួនាទី***

១-ជួយប្រធានក្នុងការសម្របសម្រួលកិច្ចប្រជុំគណៈកម្មការបណ្ដោះអាសន្ន និងគណៈកម្មការអចិន្ត្រៃយ៍

២-ជួយការងារប្រធានក្នុងការជួបប្រជុំជាមួយអង្គការជាតិ អន្តរជាតិ តំណាងស្ថានទូត និងអ្នកមានចំណាប់អារម្មណ៍ ដើម្បីផ្សព្វផ្សាយអំពី **គ ប ម** និងស្វែងរកការគាំទ្រសម្រាប់ **គ ប ម**

៣-ជួយរៀបចំអង្គសមាជដំបូង

៤-ពង្រឹង និងពង្រីក **គ ប ម** តាមមូលដ្ឋាន និងថ្នាក់ជាតិ។

*គ.២-គុណវុឌ្ឍិ*

១-មានសីលធម៌ល្អ និងមានស្មារតីលះបង់

២-មានបទពិសោធន៍ក្នុងការងារដឹកនាំស្ថាប័ន

៣-មានសមត្ថភាពសម្របសម្រួល និងចាត់ចែងការងារ។

**ឃ-តួនាទី និងគុណវុឌ្ឍិអគ្គលេខាធិការ គ ប ម**

*ឃ.១-តួនាទី*

១-ចាត់ចែងការងារប្រចាំថ្ងៃនៅក្នុងអគ្គលេខាធិការដ្ឋាន

២-ពង្រឹង និងពង្រីក **គ ប ម** តាមមូលដ្ឋាន និងថ្នាក់ជាតិ

៣-រៀបចំផែនការសកម្មភាព និងគំរោងថវិកា **គ ប ម** ថ្នាក់ជាតិ

៤-ជួយរៀបចំអង្គសមាជដំបូង។

*ឃ.២-គុណវុឌ្ឍិ*

១-មានសីលធម៌ល្អ និងមានស្មារតីលះបង់

២-មានបទពិសោធន៍ក្នុងការងារដឹកនាំស្ថាប័ន

៣-មានសមត្ថភាពសម្របសម្រួល និងចាត់ចែងការងារ។

**ង-តួនាទី និងគុណវុឌ្ឍិហេរញ្ញិក គ ប ម**

*ង.១-តួនាទី*

១-ជួយប្រធាន និងអគ្គលេខាធិការក្នុងកិច្ចការគ្រប់គ្រងហិរញ្ញវត្ថុ

២-សហការជាមួយអគ្គលេខាធិការក្នុងការរៀបចំថវិកាប្រចាំឆ្នាំ ត្រីមាស និង ខែ

៣-ផ្តល់ការគាំទ្រ និងណែនាំដល់ការគ្រប់គ្រងហិរញ្ញវត្ថុ **គ ប ម** ថ្នាក់ក្រោមជាតិ។

*ង.២-គុណវុឌ្ឍិ*

១-មានសីលធម៌ល្អ និងមានស្មារតីលះបង់

២-មានបទពិសោធន៍ក្នុងការងារគ្រប់គ្រងហិរញ្ញវត្ថុ

៣-មានសមត្ថភាពបណ្តុះបណ្តាលផ្នែកហិរញ្ញវត្ថុ។

**ឧបសម្ព័ន្ធ២៖ លក្ខណៈពិសេសរបស់ គ ប ម**

១-ប្រជាធិបតេយ្យផ្ទៃក្នុងបក្ស

- ✓ ការបោះឆ្នោតជ្រើសរើសអ្នកដឹកនាំ និងតំណាង គឺធ្វើការបោះឆ្នោតពីក្រោមឡើងលើ។
- ✓ ភាពជាម្ចាស់ និងស្វ័យភាពហិរញ្ញវត្ថុតាមរយៈក្រុមសន្សំ និងការបង់ប្រាក់សមាជិកភាព។
- ✓ សមាជិកមតិ ឬធ្វើការស្ទង់មតិសមាជិកលើការសម្រេចចិត្តសំខាន់ៗ។

២-យកមូលដ្ឋានជាធំ ឬជាគ្រឹះ

- ✓ វិមជ្ឈការ។
- ✓ បញ្ហានៅមូលដ្ឋាន ដោះស្រាយជាក់ស្តែងនៅមូលដ្ឋាន។
- ✓ ពង្រឹងសមត្ថភាពអភិវឌ្ឍ និងភាពជឿជាក់លើខ្លួនឯងរបស់អ្នកមូលដ្ឋាន។

៣-បណ្តុះអ្នកដឹកនាំនៅមូលដ្ឋាន និងតាមវិស័យ/ក្រុម

- ✓ ជ្រើសរើសបុគ្គលដែលមានគុណសម្បត្តិល្អ ដើម្បីបណ្តុះឲ្យក្លាយជាអ្នកដឹកនាំ។
- ✓ បណ្តុះបណ្តាលអ្នកដឹកនាំល្អក្នុងស្រទាប់យុវជនសម្រាប់បន្តវេន។
- ✓ បណ្តុះបណ្តាលស្ត្រីឲ្យក្លាយជាអ្នកដឹកនាំល្អ។

**ឧបសម្ព័ន្ធ៣៖ យុទ្ធសាស្ត្រនយោបាយរបស់ គ ប ម**

១-រៀបចំឲ្យមានរចនាសម្ព័ន្ធគណបក្សតាមឃុំ/សង្កាត់ រហូតដល់ថ្នាក់ជាតិ ឲ្យបាន រឹងមាំ។

២-ជ្រើសរើសបុគ្គលដែលមានគុណសម្បត្តិល្អ ឲ្យឈរឈ្មោះជាបេក្ខជនក្រុម ប្រឹក្សាឃុំ/សង្កាត់ និងតំណាងរាស្ត្រ និងធ្វើការពង្រឹងសមត្ថភាពដល់បេក្ខជន ទាំងនោះ ឲ្យទទួលបានជោគជ័យ។

៣-រៀបចំគោលនយោបាយ ឲ្យឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង របស់ឃុំ/សង្កាត់នីមួយៗ និងប្រទេសជាតិ។

៤-ធានាឲ្យមានប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយតម្លាភាព និងគណនីភាព។

៥-លើកកម្ពស់ជីវភាពសមាជិកជំហរ តាមរយៈការបង្កើតក្រុមសន្សំប្រាក់ ចូល រួមភាគហ៊ុនវិនិយោគ និងគាំទ្រឲ្យដល់ការអភិវឌ្ឍមុខរបរដល់ពួកគាត់។

៦-ធ្វើការអប់រំ និងផ្សព្វផ្សាយពី **គ ប ម** ក្នុងចំណោមសាធារណជន ជាពិសេស តាមរយៈបណ្តាញយុវជន បញ្ញាជន និងបណ្តាញផ្សេងទៀត។

៧-ពង្រឹងកិច្ចសហការជាមួយអង្គការមហាជនដូចជាអង្គការសង្គមស៊ីវិល និងប ណ្តាញក្រុមផលប្រយោជន៍ផ្សេងៗ។

៨-ធ្វើការសហការល្អជាមួយក្រុមអ្នកផ្តល់គំនិត និងផ្តល់យោបល់ផ្នែកគោល នយោបាយទៅតាមវិស័យនានា។

៩-ចលនាមហាជន ជាពិសេសយុវជន ឲ្យចូលរួមយ៉ាងសកម្មក្នុងសកម្មភាព សង្គមដូចជា ការពារធនធានធម្មជាតិ ការពារសិទ្ធិដីធ្លី ឬការពារបូរណភាព ទឹកដី និងការងារសង្គមកិច្ចផ្សេងៗ។

**ឧបសម្ព័ន្ធ៥៖ ក្រុមគោលដៅអាទិភាព និងបញ្ហាសំខាន់ៗដែលដោះស្រាយដោយ គ ប ម**

១-កសិករ (ទឹក ទីផ្សារ ទុន បច្ចេកទេស សហាគមន៍កសិកម្ម)។

២-យុវជន (ការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហគ្រិនភាព ស្រាវជ្រាវ និងវិទ្យាសាស្ត្រ ការងារ)។

៣-ពាណិជ្ជករ និងសិប្បករខ្នាតតូច និងមធ្យម (បរិយាកាសអាជីវកម្ម)។

៤-កម្មករ (ប្រាក់ខែសមស្រប ប្រព័ន្ធសុខុមាលភាពសង្គម សុវត្ថិភាពការងារ សិទ្ធិសហជីព)។

៥-មន្ត្រីរាជការ ជាពិសេសគ្រូបង្រៀន និងគ្រូពេទ្យ (ប្រាក់ខែសមស្រប និងបរិក្ខារគ្រប់គ្រាន់)។

## ឧបសម្ព័ន្ធ៥៖ ក្រុមសន្សំប្រាក់ទ្រទ្រង់ គ ប ម

ដើម្បីឲ្យសមាជិក គ ប ម មានប្រាក់ប្រើប្រាស់ជាទុនសម្រាប់កសាងជីវភាព និងបង្កើនប្រាក់ចំណូលសម្រាប់ទ្រទ្រង់ គ ប ម យើងជំរុញឲ្យមានក្រុមសន្សំប្រាក់។

*ក-គោលបំណងសំខាន់ៗរបស់ក្រុមសន្សំប្រាក់*

១-ជំរុញសាមគ្គីភាពរវាងសមាជិកជំហរ។

២-រួមគ្នាបង្កើតប្រាក់ចំណូលដើម្បីទ្រទ្រង់សកម្មភាពរួមតាមមូលដ្ឋាន។

*ខ. គោលការណ៍ក្រុមសន្សំ*

១-សមាជិកយ៉ាងតិចបំផុត១០នាក់ នៅពេលដំបូងអាចចាប់ផ្តើមពី៥នាក់។

២-សមាជិកចូលរួមប្រជុំទៀងទាត់ ១ខែ ១ដង។

៣-សមាជិកម្នាក់ៗសន្សំយ៉ាងតិចបំផុត ២០.០០០រៀល ក្នុង១ខែ។

៤-អ្នកខានមកប្រជុំ និងសន្សំ ៣ខែជាប់គ្នា (ខាន២ដងសួរនាំ) ត្រូវបញ្ឈប់ពីសមាជិកភាព និងឲ្យដើមគេវិញ។

៥-ការប្រាក់កម្ចីខ្ពស់បំផុត ១,៧% ក្នុង ១ខែ។

៦-ការប្រាក់ ៦០%ទុកប្រើប្រាស់រួម, និងច្រើនបំផុត ៤០%ផ្តល់ទៅសមាជិកជាម្ចាស់ភាគហ៊ុន។

៧-ការប្រាក់បញ្ញើពីអ្នកគាំទ្រខ្ពស់បំផុត ១%ក្នុង១ខែ ដែលប្រាក់បញ្ញើយ៉ាងច្រើនបំផុតត្រឹម ១៥ដង នៃទុនសរុបរបស់ក្រុម។

៨-សមាជិកអាចខ្ចីបានយ៉ាងច្រើនបំផុត ១០ដងនៃប្រាក់សន្សំជាមួយក្រុម។

៩-អ្នកខ្ចីត្រូវមានសាក្សីយ៉ាងតិចបំផុត២នាក់។

១០-ត្រូវមានបញ្ជីស្នាមច្បាស់លាស់ដូចជា៖

- បញ្ជីសន្សំ និងបញ្ជីបញ្ញើ
- បញ្ជីខ្ចី សង និងផាកពិន័យ
- បញ្ជីចំណាយ
- បញ្ជីចំណេញខាត

១១-មានគណៈកម្មការគ្រប់គ្រងក្រុមសន្សំ៖

- ប្រធាន
- អនុប្រធាន
- ហេរញ្ញិក
- បេឡា
- លេខាធិការ

១២-គោលការណ៍ចំណូល-ចំណាយដែលជាចំណែករបស់ក្រុម មានដូចជា៖

- ឧបត្ថម្ភគណៈកម្មការ
- បណ្តុះបណ្តាល
- ឃោសនា
- អប់រំ
- អភិវឌ្ឍន៍សហគមន៍
- សង្គមកិច្ច
- ដើមទុនវិនិយោគ
- ផ្សេងៗ

១៣-សន្សំរហូតដល់រយៈពេលយ៉ាងតិច ៣ឆ្នាំ ទើបអាចដកប្រាក់ដើមបានវិញ។

*ឧបសម្ព័ន្ធ៦៖ ឧទាហរណ៍មួយចំនួនអំពីគោលនយោបាយអភិវឌ្ឍឃុំ/សង្កាត់*

១-គោលនយោបាយដើម្បីប្រជាពលរដ្ឋទទួលបានទុន ទឹក ទីផ្សារ និងជំនាញបច្ចេកទេសកសិកម្ម។

២-គោលនយោបាយទាក់ទងនឹងសេវាសុខាភិបាលរបស់មណ្ឌលសុខភាពឃុំ/សង្កាត់។

៣-គោលនយោបាយពង្រឹងវិស័យអប់រំកំរិតមត្តេយ្យ និងបឋមសិក្សា។

៤-គោលនយោបាយបណ្តុះបណ្តាលវិជ្ជាជីវៈ ដល់យុវជន។

៥-ហេដ្ឋារចនាសម្ព័ន្ធមានគុណភាព។

៦-គាំទ្រអាជីវករ និងសិប្បករតូច និងមធ្យមតាមមូលដ្ឋាន។

៧-គោលនយោបាយគាំទ្រដល់សមាគម និងក្រុមជួយខ្លួនឯង។

៨-គោលនយោបាយពង្រឹងការសហការជាមួយអង្គការសង្គមស៊ីវិល។

៩-គោលនយោបាយអភិរក្សធនធានធម្មជាតិ និងវប្បធម៌តាមមូលដ្ឋាន។

១០-គោលនយោបាយគាំទ្រដល់ចាស់ជរា ជនពិការ និងជនងាយរងគ្រោះតាមមូលដ្ឋាន។

១១-គោលនយោបាយបង្កើនចំនួន និងពង្រឹងសមត្ថភាពស្ត្រីវ័យក្មេងឲ្យក្លាយជាអ្នកដឹកនាំ៕